DW Akademie

This project is funded by the European Union

Supported by the Federal Ministry for Economic Cooperation and Development

Women's Media Centre of Cambodia

cambodian center for independent media

អភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយ

# ការសិក្សាយេនឌឺ នៅកម្ពុជា

## ការវិភាគពីចំណេះដឹង និងឥរិយាបទរបស់យុវជនកម្ពុជា ក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយ

# សំឡេងយុវជន មានសារៈសំខាន់!

dw-akademie.com

## ប្រវត្តិរបស់ DW Akademie

DW Akademie គឺជាអង្គការឈានមុខគេរបស់ប្រទេសអាល្លឺម៉ង់សម្រាប់ការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ។ អង្គការនេះគាំទ្រការអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយសេរី និងតម្លាភាពដោយពង្រឹងគុណភាព និងសមត្ថភាពផ្នែកសារព័ត៌មាន។ DW Akademie បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង១០ឆ្នាំមកហើយ។ អង្គការនេះបាន និងកំពុងសហការជាមួយមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) និងមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) សម្រាប់គម្រោង "សំឡេងយុវជនមានសារៈសំខាន់" (២០២០-២០២២)។ គម្រោងនេះត្រូវបានគាំទ្រផ្នែកហិរញ្ញវត្ថុហិរញ្ញវត្ថុតាមរយៈជំនួយឥតសំណងរបស់សហគមន៍អឺរ៉ុបដើម្បីលើកស្ទួយលទ្ធិ-ប្រជាធិបតេយ្យ និងផ្នែកសិទ្ធិមនុស្ស។ គោលបំណងនៃគម្រោងនេះ គឺដើម្បីលើកទឹកចិត្តដល់យុវជន និងនិស្សិតនៅតាមទីក្រុង និងជនបទឱ្យប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីចូលរួមក្នុងកិច្ចពិភាក្សាជាសាធារណៈ និងដំណើរការលទ្ធិប្រជាធិបតេយ្យ។ តាមវិធីនេះយុវជននិងនិស្សិតអាចអនុវត្តសិទ្ធិរបស់ពួកគេប្រកបដោយប្រសិទ្ធភាព ចំពោះសេរីភាពក្នុងការបញ្ចេញមតិនិងការទទួលបានព័ត៌មានដូចដែលបានរៀបរាប់នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

## គោលបំណងនៃការសិក្សា

គោលបំណងនៃការសិក្សាយេនឌ័រនេះគឺ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីចំណេះដឹង និងឥរិយាបថរបស់យុវជនកម្ពុជាចំពោះប្រព័ន្ធផ្សព្វផ្សាយ និងកំណត់ពីតម្រូវការ និងចំណាប់អារម្មណ៍ក្នុងការសិក្សារបស់ពួកគេទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ (FoE) និងការទទួលព័ត៌មាន (AtI)។ លើសពីនេះទៀត ការសិក្សានេះកំណត់ពីហានិភ័យនិងបញ្ហាប្រឈមរបស់វាសម្រាប់យុវជនកម្ពុជាអាយុពី ១៥ ទៅ ៣០ ឆ្នាំ។ ការសិក្សានេះផ្តោតពិសេសទៅលើទិដ្ឋភាពយេនឌ័រ។ គោលបំណងការសិក្សានេះគឺដើម្បីកំណត់ភាពខុសប្លែកគ្នារវាងយេនឌ័រទាក់ទងនឹងចំណេះដឹងតម្រូវការសិក្សា និងចំណាប់អារម្មណ៍ព្រមទាំងហានិភ័យនិងបញ្ហាប្រឈមជាក់លាក់ដែលទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ (FoE) និងការទទួលព័ត៌មាន (AtI)។

## ក្រុម/តំបន់គោលដៅ

ការសិក្សាយេនឌ័រនេះត្រូវបានធ្វើឡើងដោយផ្អែកលើការស្ទង់មតិដែលមានអ្នកចូលរួមចំនួន ២៣៧ នាក់ (១៤១ ឬ ៦០% ជាស្ត្រី)។ អ្នកចូលរួមមានយុវជននិស្សិតសាកលវិទ្យាល័យ (និស្សិតសាកលវិទ្យាល័យជំនាញសារព័ត៌មានដែលមានចំណេះដឹងផ្នែកប្រព័ន្ធផ្សព្វផ្សាយកម្រិតខ្ពស់ និងនិស្សិតក្នុងវិស័យផ្សេងទៀត [សិស្សទូទៅ]) និងអ្នកជំនាញសារព័ត៌មានវ័យក្មេង។ ក្រុមទាំងបីនេះយល់ស្របជាមួយគោលដៅសំខាន់នៃគម្រោង "សំឡេងយុវជនមានសារៈសំខាន់"។ នៅក្នុងការសិក្សានេះក្រុមទីពីរត្រូវបានបែងចែកបន្តទៀតដើម្បីពិចារណាពីកម្រិតខុសៗគ្នានៃជំនាញប្រព័ន្ធផ្សព្វផ្សាយរវាងនិស្សិតប្រព័ន្ធផ្សព្វផ្សាយនិងនិស្សិតក្នុងវិស័យផ្សេងទៀត។ អ្នកចូលរួមមកពីទីក្រុងភ្នំពេញ ខេត្តបាត់ដំបង និងសៀមរាប។

### តើអ្នកគិតថាយុវជនកម្ពុជាអាចបញ្ចេញមតិ ឬគំនិតរបស់ពួកគេជាសាធារណៈដោយសេរីបានដែរឬទេ?

បែងចែកតាមប្រភេទអ្នកឆ្លើយតប




**រូបភាពទី១:** កម្រិតនៃសេរីភាពនៃការបញ្ចេញមតិ
ប្រភព៖ ការស្រាវជ្រាវផ្ទាល់ខ្លួន។ លេខគិតជាភាគរយ។

### តើអ្នកគិតថាអ្នកមានសិទ្ធិពេញលេញក្នុងការទទួលបានព័ត៌មាន ដែលអ្នកចង់ទទួលដែរឬទេ?

អ្នកឆ្លើយតបសរុប: ២២៨ នាក់




**រូបភាពទី២:** កម្រិតនៃការទទួលបានព័ត៌មាន
ប្រភព៖ ការស្រាវជ្រាវផ្ទាល់ខ្លួន។ លេខគិតជាភាគរយ។

# វិធីសាស្ត្រ

ការសិក្សាត្រូវបានធ្វើឡើងជាមួយអ្នកឆ្លើយតបទាំងអស់តាមអីុនធឺណិត។ កម្រងសំណួរមានសំណួរទាក់ទងនឹងចំណេះដឹងនិងតម្រូវការសិក្សារបស់ពួកគេ ព្រមទាំងបញ្ហាប្រឈមទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ (FoE) និងការទទួលព័ត៌មាន (AtI) ។ ដោយសារចំនួនអ្នកចូលរួមមានកំណត់លទ្ធផលមិនតំណាងឱ្យមតិឬឥរិយាបថ ទូទៅរបស់យុវជនកម្ពុជាទាំងអស់ទេ។ កម្រងសំណួររួមបញ្ចូលសំណួរពហុជម្រើស និងសំណួរបើកចំហ។ អនុសាសន៍ត្រូវបានបង្កើតឡើងដោយផ្អែកលើលទ្ធផលនៃការស្ទង់មតិសម្រាប់ការអនុវត្តគម្រោង។

# ចំណុចសំខាន់ៗដែលបានរកឃើញ

## អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មាន (MIL)

ចំណេះដឹងរបស់អ្នកចូលរួមអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មាន (MIL) មានកំណត់។ ៣៩%នៃអ្នកឆ្លើយតបទាំងអស់បានឮឬបានដឹងអំពីរឿងនេះ។ នៅទីនេះភាពខុសគ្នា រវាងយេនឌ័រគឺគួរឱ្យកត់សម្គាល់។ ពាក់កណ្ដាលនៃបុរសអ្នកឆ្លើយតប(៥១%) បានបង្ហាញពីចំណេះដឹងមូលដ្ឋានអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មាន (MIL) ប៉ុន្តែខាងស្រីវិញមានតែមួយភាគបី (៣១%)ប៉ុណ្ណោះ។ ខណៈពេលដែលចំណេះដឹងអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មាន (MIL) មានកំរិតទាប អ្នកចូលរួម (៦៨%) យល់ពីតួនាទីនិងមុខងារទូទៅនៃប្រព័ន្ធផ្សព្វផ្សាយនៅក្នុងសង្គមប្រជាធិបតេយ្យ។ អ្នកសារព័ត៌មាន អ្នកជំនាញខាងប្រព័ន្ធផ្សព្វផ្សាយ និងនិស្សិតប្រព័ន្ធផ្សព្វផ្សាយយល់ច្បាស់អំពីរឿងនេះ (១០០%) ប៉ុន្តែការយល់ដឹងអំពីប្រធានបទនេះមានកម្រិតទាបជាងចំណោមយុវជន (៦០%) និងនិស្សិតសាកលវិទ្យាល័យទូទៅ។

## សេរីភាពនៃការបញ្ចេញមតិ (FoE)

អ្នកឆ្លើយតបភាគច្រើន(៧៣%)យល់ដឹងពីសេរីភាពក្នុងការបញ្ចេញមតិក្នុងកម្រិតមូលដ្ឋាន។ ខណៈពេលដែលមនុស្សជាច្រើនយល់ដឹងពីសេរីភាពនៃការបញ្ចេញមតិ (FoE) មានមនុស្សតិចជាងយល់ឃើញថាយុវជនខ្មែរអាចបញ្ចេញមតិរបស់ពួកគេជាសាធារណៈដោយសេរី។ ទោះយ៉ាងណា បើមើលទៅក្នុងក្រុមស្ទង់មតិដោយលម្អិតយើងឃើញថាមានតែ៣៦% នៃអ្នកសារព័ត៌មាននិងអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយយល់ស្របនឹងមតិនេះ។ ផ្ទុយទៅវិញ ៧៩% នៃយុវជនជឿជាក់ថាពួកគេអាចបញ្ចេញមតិដោយសេរីនៅទីសាធារណៈ។ ភាពខុសគ្នាមួយទៀតគឺបុរស (៧១%) ច្រើនជាងយុវនារី (៦៣%) មានអារម្មណ៍ថាពួកគេអាច បញ្ចេញមតិរបស់ពួកគេដោយសេរីតាមទីសាធារណៈ។ នៅពេលឱ្យពន្យល់ពីរឿងនេះ អ្នកចូលរួមបានលើកឡើងពីការរើសអើងចំពោះស្ត្រី សម្ពាធសង្គម ភាពខ្មាស-អៀន និងការប្រកាន់ខ្ជាប់ទៅនឹងទំនៀមទម្លាប់ ឥរិយាបថ និងប្រពៃណី។ មានតែ២៣% នៃអ្នកចូលរួមប៉ុណ្ណោះគិតថាអ្នកបង្កើតគោលនយោបាយទទួលយកមតិឬសំឡេងដែលឆ្លុះបញ្ចាំងតាមរយៈប្រព័ន្ធផ្សព្វផ្សាយដើម្បីពិចារណានៅពេលធ្វើការសម្រេចចិត្ត។ មានបុរស ១០%ច្រើនជាងយុវនារីគិតថាមតិរបស់ពួកគេសំខាន់ក្នុងកម្រិតនយោបាយ។ អ្នកឆ្លើយតបយល់ឃើញថាហានិភ័យឬបញ្ហាប្រឈមចម្បងចំពោះសេរីភាពនៃការបញ្ចេញមតិ (FoE) របស់ពួកគេគឺជាការគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ។

## ការទទួលព័ត៌មាន (AtI)

ពាក់កណ្ដាលនៃអ្នកចូលរួម (៥០%) បានបញ្ជាក់ថាពួកគេ “បានដឹង ឮ និងរៀនអំពី ការទទួលព័ត៌មាន (AtI) រួចទៅហើយ” ខណៈពេលដែលមួយភាគបីនៃអ្នកចូលរួមបាននិយាយថាពួកគេមិនប្រាកដ (៣៣%) តិចជាងមួយភាគបួន (១៧%) មិនធ្លាប់ឮអំពីរឿងនេះ។ នៅទីនេះមិនមានភាពខុសគ្នារវាងយេនឌ័រទាក់ទងនឹងចំណេះដឹងរបស់ការទទួលព័ត៌មាន (AtI)។ អ្នកចូលរួមក្នុងការស្ទង់មតិទទួលបានព័ត៌មានភាគច្រើនតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ៣ ប្រភេទ: ១) ប្រព័ន្ធអីុនធឺណិត (៩១%), ២)ប្រព័ន្ធផ្សព្វផ្សាយដូចជាទូរទស្សន៍និងវិទ្យុ (៤៣%), ៣)ប្រព័ន្ធផ្សព្វផ្សាយ បោះពុម្ព (២០%)។ អ្នកចូលរួមបានបង្ហាញចំណាប់អារម្មណ៍ពិសេសក្នុងការទទួលបានព័ត៌មានអំពីបញ្ហាសង្គម (៧៧%) ការអប់រំ ការងារ/អាជីព (៧១%) សុខភាព (៧១%) និងនយោបាយ (៦៣%)។ ប៉ុន្តែស្ទើរតែពាក់កណ្ដាលនៃអ្នកចូលរួម(៤៦%) គិតថាពួកគេមិនមានសិទ្ធិក្នុងការទទួលបានព័ត៌មានដែលពួកគេចង់បានដោយសារតែ ១) ព័ត៌មានក្លែងក្លាយ; ២)ឥទ្ធិពលរបស់រដ្ឋាភិបាលលើប្រព័ន្ធផ្សព្វផ្សាយ; ៣) ភាពលំអៀងនៃប្រព័ន្ធផ្សព្វផ្សាយ; ៤) ការត្រួតពិនិត្យនៃព័ត៌មានដែលផ្សព្វផ្សាយទៅ (ឧទាហរណ៍: នយោបាយ)។ លទ្ធផលដែលទទួលបានគួរឱ្យភ្ញាក់ផ្អើលព្រោះ ៧៩% នៃអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយនិងអ្នកកាសែតជឿថាសិទ្ធិនៃការទទួលបានព័ត៌មានរបស់ពួកគាត់មានកំណត់ ប៉ុន្តែមានតែ៣៧%នៃនិស្សិតសាកលវិទ្យាល័យឯកទេសប្រព័ន្ធផ្សព្វផ្សាយដែលគិតដូច្នេះ។ ក្នុងការស្ទង់មតិ មានតែ ១៦% នៃអ្នកចូលរួមទាំងអស់ប៉ុណ្ណោះជឿជាក់ថាពួកគេអាចទទួលបានព័ត៌មានពេញលេញ។ អ្នកចូលរួមយល់ថា “ព័ត៌មាននយោបាយ” គឺជាព័ត៌មានពិបាករកបំផុត(៧៧%) អមដោយ “ច្បាប់និងឧក្រិដ្ឋកម្ម” (៤៣%) និង “បញ្ហាសង្គម” (៣៧%)។ ឧបសគ្គឬការលំបាកទាក់ទងនឹងការទទួលព័ត៌មាន(AtI)ដែលអ្នកឆ្លើយ (អ្នកចូលរួម) ច្រើនរាយការណ៍គឺ ១) ព័ត៌មានមិនពិត ព័ត៌មានមិនត្រឹមត្រូវនិងកង្វះធនធានដែលអាចទុកចិត្តបាន ២) កង្វះទំនុកចិត្តលើព័ត៌មាន ៣) កង្វះប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ៤)ការគ្រប់គ្រងរបស់រដ្ឋាភិបាល ៥) ងាយរងគ្រោះដោយវីរុសកំព្យូទ័រ។ ច្រើនជាងមួយភាគបួន (២៧%) នៃអ្នកចូលរួមទាំងអស់មើលឃើញភាពខុសគ្នារវាងរបៀបដែលយុវនារីនិងបុរសប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីទទួលបានព័ត៌មាន, ប៉ុន្តែ ១/៤ ទៀត (២៥%) មិនជឿថាមានភាពខុសគ្នាទេ។ ហេតុផលដែលត្រូវបានលើកឡើងញឹកញាប់បំផុតសម្រាប់ភាពខុសគ្នារវាងយេនឌ័រក្នុងការទទួលបានព័ត៌មានគឺ“ ភាពខុសគ្នានៃជំនាញក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ”។ យុវតីខ្មែរមិនមានការជឿនលឿននៅក្នុងវិស័យនេះនៅឡើយទេ។

## ការចូលរួមក្នុងគម្រោងស្ដីពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន

អ្នកឆ្លើយតបភាគច្រើនមានការចាប់អារម្មណ៍ក្នុងការចូលរួមក្នុងគម្រោងយុវជនអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មាន(MIL)។ នៅទីនេះមិនមានភាពខុសគ្នារវាងយេនឌ័រទេ។ ទោះយ៉ាងណាចំនួនអ្នកដែលចង់ចូលរួមក្នុងកម្មវិធីបែបនេះមានអ្នកជំនាញខាងប្រព័ន្ធផ្សព្វផ្សាយវ័យក្មេងនិងអ្នកសារព័ត៌មាន (៩៣%) ច្រើនជាងយុវជន (៨៣%) និស្សិតសាកលវិទ្យាល័យផ្នែកប្រព័ន្ធផ្សព្វផ្សាយ(៧៧%) និងនិស្សិតសាកល វិទ្យាល័យទូទៅ (៥៧%)។ ប្រធានបទចម្បងដែលពួកគេ




**រូបភាពទី៣:** ឥទ្ធិពលនៃការបញ្ចេញមតិរបស់យុវជនក្នុងប្រព័ន្ធផ្សព្វផ្សាយទៅលើអ្នកបង្កើតគោលនយោបាយ
ប្រភព៖ ការស្រាវជ្រាវផ្ទាល់ខ្លួន។ លេខគិតជាភាគរយ ចំនួនសរុបត្រូវបានបង្គត់?។

ចាប់អារម្មណ៍គឺៈ ១)អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មាន(MIL), សេរីភាពនៃការបញ្ចេញមតិ (FoE) និងការទទួលព័ត៌មាន (AtI) ទូទៅ ២) ច្បាប់និងសិទ្ធិទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ(FoE)និងការទទួលព័ត៌មាន (AtI) ៣) វេទិកាប្រព័ន្ធផ្សព្វផ្សាយផ្សេងៗគ្នា ៤) សន្តិសុខនិងសុវត្ថិភាពក្នុងការប្រើប្រព័ន្ធផ្សព្វផ្សាយ ៥)កំណត់និងវិភាគព័ត៌មានពិតធៀបនឹងព័ត៌មានមិនពិត ៦) សមភាពយេនឌ័រនៅក្នុងវិស័យសារព័ត៌មាន។ អ្នកឆ្លើយសំណួរចង់ទទួលបានការពង្រឹងសមត្ថភាពក្នុង

វិស័យសារព័ត៌មានតាមរយៈសកម្មភាពដូចជា ១)សិក្ខាសាលាប្រព័ន្ធផ្សព្វផ្សាយ/កម្មវិធី/វេទិកាសាធារណៈព្រមទាំង២)ការបណ្តុះបណ្តាលនិងហ្វឹកហាត់។ ពួកគេក៏ចាប់អារម្មណ៍លើព័ត៌មានទូទៅអំពីការអប់រំប្រព័ន្ធផ្សព្វផ្សាយ,សម្ភារៈសិក្សានិងខិត្តប័ណ្ណ។ កង្វល់ទូទៅទាក់ទងនឹងហានិភ័យដែលអាចកើតមាននៃ ការចូលរួមក្នុងសិក្ខាសាលាអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មានគឺ ១) ស្វែងរកពេលវេលាសម្រាប់វា ២)បញ្ហានយោបាយ ៣)សុវត្ថិភាព/ សន្តិសុខផ្ទាល់ខ្លួន ៤) សម្ពាធសង្គមនិងគ្រួសារ។ មានតែអ្នកចូលរួមតិចតួចប៉ុណ្ណោះដែលនិយាយថាពួកគេព្រួយបារម្ភអំពី ហានិភ័យសុខភាពទាក់ទងនឹង កូវីត១៩។

## ការវិភាគគម្លាតយេនឌ័រ

៤១%នៃអ្នកចូលរួមការសិក្សាទាំងអស់គិតថាបុរសនិងស្ត្រីត្រូវបានគេឱ្យតម្លៃស្មើគ្នានៅក្នុងសង្គមកម្ពុជា ។ អ្នកចូលរួមចំនួន ៣៩%ទៀតមិនយល់ស្រប។ ខណៈពេលដែល ៤៤% នៃបុរសដែលឆ្លើយតបទាំងអស់ ជឿជាក់ថាបុរសនិងស្ត្រីត្រូវបានគេឱ្យតម្លៃស្មើគ្នា មានតែ៣៩%នៃស្ត្រីទាំងអស់ប៉ុណ្ណោះយល់ព្រមជាមួយមតិនេះ។ អ្នកឆ្លើយតបទាំងនោះដែលជឿថា ជនជាតិកម្ពុជាមានសមភាពយេនឌ័រសង្កត់ធ្ងន់ថាបុរសនិងស្ត្រីស្មើភាពគ្នានៅមុខច្បាប់ព្រោះពួកគេមានសិទ្ធិដូចគ្នា និងមានឱកាសដូចគ្នាក្នុងការអប់រំនិងការដឹកនាំ។ មួយភាគបីនៃអ្នកឆ្លើយតប (៣១%) បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលអំពីបញ្ហាយេនឌ័ររួចទៅហើយ ប្រៀបធៀបទៅនឹងស្ទើរតែពាក់កណ្តាលនៃអ្នកឆ្លើយតបទាំងអស់ (៤៦%) ដែលមិនធ្លាប់ចូលរួមសិក្ខាសាលាលើប្រធានបទនេះ។ លទ្ធផលនេះអនុវត្តទៅលើស្ត្រី និងបុរស។

## អនុសាសន៍

ការសិក្សាយេនឌ័រនេះបានកំណត់ពីតម្រូវការសំខាន់ចំណាប់អារម្មណ៍ ហានិភ័យនិងបញ្ហាប្រឈម សម្រាប់ការអនុវត្តគម្រោងយុវជន អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មាន (MIL) ដោយផ្តោតលើការទទួលព័ត៌មាន (ATI) និង សេរីភាពនៃការបញ្ចេញមតិ (FoE) នៅកម្ពុជា ហើយដោយផ្អែកលើលទ្ធផលនៃការស្ទង់មតិ

## បានផ្តល់អនុសាសន៍ដូចខាងក្រោម

- ធានាឱ្យមានការចូលរួមទាំងស្ត្រី និងបុរសនៅក្នុងគម្រោងនេះ ចាត់វិធានការ សកម្មដើម្បីផ្តល់ឱ្យយុវនារីនូវ កន្លែងគ្រប់គ្រាន់ដើម្បី បង្ហាញពី កង្វល់និងគំនិតរបស់ពួកគេ។ ផ្តល់ការប្រឹក្សានិងការបណ្តុះបណ្តាលប្រសិន បើចាំបាច់។ យើងត្រូវកំណត់ថា ភាពអៀនខ្មាស់ដោយសារប្រពៃណីនិងតួនាទីយេនឌ័រអាចរារាំងការចូលរួម របស់ស្ត្រីប្រកបដោយភាពជោគជ័យ។

- ប្រើវេទិកាសិក្សា ឬវេទិកាទុកចិត្តផ្សេងទៀត ដើម្បីជូនដំណឹង ដល់យុវជន និងសាធារណជនទូទៅអំពី គម្រោងនេះ។ វាក៏អាចជួយ ឪពុកម្តាយ ឬអាណាព្យាបាលយល់ពីសារៈសំខាន់នៃការអនុញ្ញាតឱ្យកូនៗរបស់ពួកគេចូលរួមសកម្មភាពនិងគម្រោងផ្សេងៗ។ ទ្រង់ទ្រាយវេទិកាអាចជាវីដេអូខ្លី ពន្យល់ពីគម្រោងជាភាសាខ្មែរដែលនឹងត្រូវចែករំលែកតាមបណ្តាញសង្គមហើយយុវជនអាចបង្ហាញទៅឪពុកម្តាយរបស់ពួកគេ។

- ប្រើវិធីសាស្ត្រ បណ្តុះបណ្តាលជាច្រើន; ព្រមទាំងផ្តល់សិក្ខាសាលាមួយចំនួនដើម្បីធ្វើឱ្យយុវជនងាយស្រួល ចូលរួម។ រួមទាំងការបណ្តុះបណ្តាល/ការប្រឹក្សាផ្ទាល់ខ្លួននិងការបណ្តុះបណ្តាលតាមអ៊ីនធឺណិត ។យេនឌ័រគឺ ជាប្រធានបទថ្មីមួយសម្រាប់អ្នកចូលរួមភាគច្រើនដូច្នេះយើងត្រូវផ្តល់វេទិកាមូលដ្ឋានអំពីសមភាពយេនឌ័រនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។

- ធ្វើការវាយតម្លៃមុន និងក្រោយព្រមទាំងការធ្វើតេស្តក្រោយដោយ អនាមិកដើម្បីឱ្យអ្នកចូលរួមជាពិសេសស្ត្រីមានសេរីភាពក្នុងការ បញ្ចេញមតិរបស់ពួកគេ។

- ប្រធានបទដែលអាចប៉ះពាល់សតិអារម្មណ៍ចាំបាច់ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃហានិភ័យ និងបញ្ហាប្រឈមចំពោះការអនុវត្តគម្រោងប្រកបដោយភាពជោគជ័យ ។វាគួរតែត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការវគ្គសិក្សា ឬ កម្មវិធីសិក្សាណាមួយ ។ អ្នកបណ្តុះបណ្តាលត្រូវមានជំនាញវិជ្ជាជីវៈនិងដឹងពីរបៀបដោះស្រាយ បញ្ហាដែលអាចប៉ះពាល់សតិអារម្មណ៍ទំាងនេះកំឡុងពេល បណ្តុះបណ្តាលដើម្បីចៀសវាងពាក្យបណ្តឹងពី ភាគីពាក់ព័ន្ធដែលមិនចូលរួមផ្ទាល់។

## DW Akademie

DW Akademie គឺជាមជ្ឈមណ្ឌលរបស់ Deutsche Welle សម្រាប់ការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ ការបណ្តុះបណ្តាលសារព័ត៌មាន និងការផ្ទេរចំណេះដឹង។ គម្រោងរបស់យើងពង្រឹងសិទ្ធិមនុស្សដើម្បីឱ្យមានសេរីភាពក្នុងការបញ្ចេញមតិនិងការទទួលបានព័ត៌មានដោយគ្មានឧបសគ្គ។ DW Akademie ផ្តល់អំណាចដល់ប្រជាជនទូទាំងពិភពលោកដើម្បីធ្វើការសម្រេចចិត្តឯករាជ្យដោយផ្អែកលើការពិតដែលអាចជឿទុកចិត្តបាននិងការសន្ទនាមានអត្ថប្រយោជន៍។

DW Akademie គឺជាដៃគូយុទ្ធសាស្ត្ររបស់ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍសេដ្ឋកិច្ច ។ ពួកយើងក៏ទទួលបានមូលនិធិពីក្រសួងការបរទេសរបស់សហព័ន្ធ និងពីសហភាពអឺរ៉ុបផងដែរ។ លើសពីនេះ ពួកយើងក៏ធ្វើការយ៉ាងសកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ប្រមាណជាង៥០ប្រទេស។

### ទំនាក់ទំនង

DW Akademie
Media Development Asia-Europe
Kurt-Schumacher-Str. 3
53113 Bonn | Germany
dw-akademie.phnom-penh@dw.com

DWAkademie.Asia
@dw_akademie
DWAkademie
dw.com/newsletter-registration
dw.com/mediadev

*This publication was produced with the financial support of the European Union. Its contents are the sole responsibility of DW Akademie and do not necessarily reflect the views of the European Union.*
*© 2021 DW Akademie. All rights reserved. Licensed to the European Union under conditions.*